ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ
លេខ......០៣០......ក.ជ.គ........

ថ្ងៃ ៥រោច ១០កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៩

## សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

អនុលោមតាមប្រកាសលេខ ៣៣៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ និងដើម្បីផ្តល់ពេលវេលាបន្ថែមជូនអង្គភាពមិនស្វែងរកប្រាក់ចំណេញក្នុងការស្វែងយល់និងត្រៀមលក្ខណៈអនុវត្តឱ្យបានល្អប្រសើរនូវស្តង់ដារបាយការណ៍ហិរញ្ញវត្ថុដែលបានដាក់ឱ្យអនុវត្តកន្លងមក ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនដំណឹងដល់គ្រប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលកំពុងធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបដូចតទៅ÷

១- ក្រុមប្រឹក្សាជាតិគណនេយ្យ សម្រេចពន្យារពេលអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ រហូតដល់មានការជូនដំណឹងសារជាថ្មី។

២- គ្រប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ អាចបន្តប្រើស្តង់ដាគណនេយ្យ ឬមូលដ្ឋានគណនេយ្យបច្ចុប្បន្ន ដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៨ ដូចដែលធ្លាប់បានអនុវត្តនាពេលកន្លងមក។

៣- ក្នុងករណី អង្គភាពមិនស្វែងរកប្រាក់ចំណេញ ពុំធ្លាប់មានស្តង់ដារបាយការណ៍ហិរញ្ញវត្ថុសម្រាប់ប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ អង្គភាពមិនស្វែងរកប្រាក់ចំណេញទាំងនោះ អាចប្រើស្តង់ដារបាយកាណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញបាន។

៤- គ្រប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ តាមពេលកំណត់ដូចមានចែងក្នុងព្រះរាជក្រម នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងត្រូវផ្ញើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួនមកក្រុមប្រឹក្សាជាតិគណនេយ្យតាមប្រព័ន្ធគ្រប់គ្រងសេវាសាធារណៈ (www.naccambodia.gov.kh)។

៥- ក្រុមប្រឹក្សាជាតិគណនេយ្យ នឹងបន្តផ្សព្វផ្សាយនិងបណ្តុះបណ្តាលអំពីបច្ចេកទេសស្តង់ដាដែលមានជាធរមាន ព្រមទាំងបន្តរៀបចំស្តង់ដាបាយការណ៍ហិរញ្ញវត្ថុដែលអាចឆ្លើយតបបន្ថែមទៀតទៅនឹងតម្រូវការរបស់អង្គភាពមិនស្វែងរកប្រាក់ចំណេញ។

អាស្រ័យហេតុនេះ សូមអង្គភាពមិនស្វែងរកប្រាក់ចំណេញទាំងអស់ ជ្រាបជាព័ត៌មាន និងត្រូវអនុវត្តនូវសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ

ចិ_តាឃី

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
Website: www.naccambodia.gov.kh
Email : info@naccambodia.gov.kh
ទូរស័ព្ទ: ៨៥៥-២៣ ៤៣២ ១៥៤ / ៨៥៥-២៣ ៤៣២ ១៧៤
Phone: 023 432 154 / 023 432 174